# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីពុទ្ធភាសិតមួយបទពោលថា ជំនះណាដែលចាញ់វិញ ជំនះនោះពុំប្រសើរឡើយ ឯជំនះណាពុំត្រឡប់ចាញ់វិញ ទើបជាជំនះប្រសើរ

web site: hoksavann.org

ថ្ងៃទី១១ មិថុនា ២០០៥

ពុទ្ធភាសិតថា ជំនះណាដែលត្រឡប់ចាញ់វិញ ជំនះនោះពុំប្រសើរ ឯជំនះណាដែលមិនត្រឡប់ចាញ់វិញ ទើបជាជំនះប្រសើរនោះ ចេញមកពីបាលីថា ន តំ ជិតំ សាធុ ជិតំ អវជីយ្យតិ តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជិយ្យតិ ។

ជំនះណាដែលត្រឡប់ចាញ់វិញ ជាជំនះពុំប្រសើរនោះ ដូចជាជំនះដោយល្បែងស៊ីសង មានបៀអាប៉ោងកាស៊ីណូជាដើម តែងត្រឡប់ចាញ់វិញ ។ ធម្មតាអ្នកលេងល្បែងតែងមានឈ្នះមានចាញ់ ហើយអ្នកលេងល្បែងពុំសូវលេងតែម្ដងហើយឈប់ទេ ច្រើនតែញៀនលេងពុំឈប់ចេះតែលេងជាបន្តទៅទៀត ដោយគិតថា ក្រែងឈ្នះបានច្រើនជាងនេះលេងយូរៗទៅ ក៏ចាញ់អស់ទាំងចុងអស់ទាំងដើម ។ អ្នកញៀននឹងការលេងល្បែង ជួនកាលលក់របស់របរទៅលេងទៀត នាំឲ្យខ្វែងគំនិតគ្នាក្នុងគ្រួសារ រហូតបង្កើតជម្លោះបាក់បែកគ្នាថែមទៀត ។ ជួនកាលកើតជាចោរលួចប្លន់ បើអ្នករដ្ឋការវិញ កើតការពុករលួយស៊ីសំណូកដើម្បីបានប្រាក់លេងល្បែង ។ ជំនះដោយការវាយតប់គ្នា ឈ្នះគេពេលនេះពេលក្រោយគេរកមធ្យោបាយយកឈ្នះវិញ គឺជាជំនះប្រកបដោយការចងពៀរគ្នា ។ ឯជំនះដោយការធ្វើចម្បាំងក៏ដូចគ្នា តែងមានចាញ់មានឈ្នះ ហើយជំនះក៏ពុំបានស្ថិតស្ថេរដែរ បើពុំបាននិយាយចរចាគ្នាបញ្ឈប់សង្គ្រាមទេ ។ ព្រះពុទ្ធសាសនាបានបង្រៀនឲ្យមនុស្សដោះស្រាយបញ្ហាដោយសន្តិវិធី ឆ្លងតាមការនិយាយគ្នា កុំប្រើហឹង្សាដោយយុទ្ធវិធី ព្រោះការធ្វើចម្បាំងតែងខូចខាតទាំងទ្រព្យសម្បត្តិ ទាំងជីវិតមនុស្ស ហើយរមែងចងពៀរនឹងគ្នាទៀតផង ។

ជំនះណាដែលពុំត្រឡប់ចាញ់វិញ ទើបជាជំនះប្រសើរនោះ គឺឈ្នះនូវសេចក្ដីអាក្រក់ខ្លួនឯង ឈ្នះនូវកិលេសតណ្ហាដែលស្ថិតនៅក្នុងចិត្តមនុស្សសត្វ ។ ឫសគល់ដែលនាំឲ្យមនុស្សសត្វធ្វើអាក្រក់បានដល់អកុសល៣យ៉ាង គឺលោភៈ ទោសៈ និង មោហៈ ។ ជនឈ្នះនូវសេចក្ដីអាក្រក់ ឈ្មោះថាជាជនមានចិត្តបរិសុទ្ធ ដែលជាជនពុំបៀតបៀនអ្នកដទៃ ដែលភាសាផ្លូវលោកហៅថា ការគោរពសិទ្ធិមនុស្សនេះឯង ។ ការពុំបៀតបៀនអ្នកដទៃរមែងបានសេចក្ដីសុខ ព្រោះពុំមានសត្រូវខាងក្រៅ ដោយបានកំចាត់បង់សត្រូវខាងក្នុង គឺសេចក្ដីអាក្រក់ក្នុងចិត្តរបស់ខ្លួននេះឯង ។ បើឈ្នះសត្រូវក្នុងខ្លួនហើយ សត្រូវខាងក្រៅក៏ឈ្មោះថាឈ្នះហើយដែរ ។ ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្នះមារ គឺឈ្នះកិលេសតណ្ហាក្នុងព្រះទ័យព្រះអង្គ ដោយកំចាត់បង់មិនឲ្យកើតមានដោយព្រះអរិយមគ្គ ៕

⌘